K03319
TSL Box 4

# ករណី សៅ យ៉ុន

អាយុ ៣១ ។ ប្រុស ។ ខ្មែរ ។ មានគ្រួសារ ។

- អតីត: កម្មករ រោងចក្រកៅស៊ូ កង់ឡាន តាខ្មៅ ។

- បច្ចុប្បន្ន : កម្មករ " ក១ " ។

- បានទទួលការអប់រំ និងអូសទាញចូលសេអ៊ីអា ពីឈ្មោះ ពិត ថា -សេ៦៨ នាយក្រសួងផលិតកម្ម បច្ចុប្បន្ន: មិនដឹង - និង អ៊ុំ ស៊ីនឿន -សេបច្ចុប្បន្ន មិនដឹង - ។

១៩៧២ • បានចូល សេ អ៊ី អា នៅរោងចក្រកង់ឡាន តាខ្មៅ

អ្នកនាំចូល ពិត ថា

អ្នកទទួលស្គាល់ អ៊ុំ ស៊ីនឿន

ប្រាក់ខែ ៥ ម៉ឺន រៀល

ភារកិច្ច ឃោសនាប្រឆាំងកុម្មុយនីស្ត គាំទ្ររបបលោកសេរី គាំទ្ររបប សាធារណរដ្ឋ និងស៊ើបរកបណ្ដាញខ្មែរក្រហម ក្នុងនិងក្រៅរោងចក្រ ។

<u>សកម្មភាព</u> • ក្រោយ ១៧.៤.៧៥ :

បានធ្វើសកម្មភាពសេ អ៊ី អា ក្នុងក្រុម គឹម សុផានី ។

- បានឃោសនាបំផុសបំផុល ឱ្យកម្មករចាស់ ប្រឆាំងបដិវត្ត ឱ្យទាមទារ

ជីវភាពរស់នៅឯកជន ធ្វើការតិចម៉ោង ឱយលាក់ចំណេះ
បច្ចេកទេស ព្រោះបើបង្រៀនកម្មករថ្មីចេះអស់ អង្គការនឹង
ជំលៀសពួកកម្មករចាស់ទៅជនបទអស់ហើយ ។

- បានចលនាកម្មករចាស់ឱយត្រៀមធ្វើឱយរោងចក្រគាំដំណើរការ ជាទូទៅ កាលណា អង្គការជំលៀសពួកគេទៅជនបទ ។
- បានធ្វើឱយម៉ាស៊ីនអាក់រអួលជាញឹកញាប់ ។